01321882

**Declassified to Public**
**28 June 2019**

លេខ៖ D302/3

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**Kingdom of Cambodia**
**Nation Religion King**

**Royaume du Cambodge**
**Nation Religion Roi**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des Tribunaux cambodgiens

ឯកសារទទួល
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/Date de reception): 25 / 08 / 2016
ម៉ោង (Time/Heure): 13:10
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

**ការិយាល័យសហចៅក្រមស៊ើបអង្កេត**
**Office of the Co-Investigating Judges**
**Bureau des co-juges d'instruction**

**សំណុំរឿងលេខ៖ ០០៤/០៧-០៩-២០០៩-អ.វ.ត.ក -ក.ស.ច.ស**

ចំពោះមុខ ៖ សហចៅក្រមស៊ើបអង្កេត

កាលបរិច្ឆេទ ៖ ថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ២០១៦

ភាសា ៖ ខ្មែរ/អង់គ្លេស [អង់គ្លេស ភាសាដើម]

ចំណាត់ថ្នាក់ឯកសារ ៖ **សម្ងាត់**

---

# សេចក្តីជូនដំណឹងអំពីការផ្អាកកិច្ចស៊ើបសួរទាក់ទងនឹងការចោទប្រកាន់នីមួយៗ

---

**<u>ផ្ញើជូន៖</u>**

**សហព្រះរាជអាជ្ញា**
ជា លាង
Nicholas KOUMJIAN

**មេធាវីការពារក្តីអោ អាន**
មុំ លុជ្ស
Richard ROGERS
Göran SLUITER

**មេធាវីការពារក្តី យឹម ទិត្យ**
សូ មូស្សេទ្ធី
Suzana TOMANOVIĆ

**សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី**
ជេត វណ្ណលី
ហុង គឹមសួន
គីម ម៉េងឃី
ឡោ ជុនធី
សំ សុគង់
ស៊ិន ស៊ីវ៉ន
ទី ស្រ៊ីនណា
វ៉ែន ពៅ
Linda BEHNKE
Laure DESFORGES NZEPA
Herve DIAKIESE
Ferdinand DJAMMEN-NZEPA
Nicole DUMAS
Isabelle DURAND
Françoise GAUTRY
Emmanuel JACOMY
Martine JACQUIN
Christine MARTINEAU
Barnabe NEKUI
Lyma NGUYEN
Beini YE

## I. ប្រវត្តិនីតិវិធី និងសារណា

១. នៅថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ២០១៦ នៅក្នុងសំណើសុំមតិយោបល់ទាក់ទងនឹងការចោទប្រកាន់អំពីអង្គហេតុដែលនឹងមិនស៊ើបអង្កេតថែមទៀតទេ("សំណើសុំមតិយោបល់")[1] ខ្ញុំបានជូនដំណឹងភាគីទាំងអស់អំពីគោលបំណងរបស់ខ្ញុំដែលមិនចង់ស៊ើបអង្កេតថែមទៀតលើអង្គហេតុដូចខាងក្រោម[2]ដែលបានចោទនៅក្នុងដីកាសន្និដ្ឋាន។

- **អង្គហេតុទី ១**- ការចោទប្រកាន់ទាំងអស់ទាក់ទងនឹងមន្ទីរសន្តិសុខវត្តសុបិន[3]។
- **អង្គហេតុទី ២** - ការចោទប្រកាន់ទាំងអស់ទាក់ទងនឹងភូមិសោម[4]។
- **អង្គហេតុទី ៣** -ការចោទប្រកាន់ទាក់ទងនឹងការដាក់គោលដៅ ការចាប់ខ្លួន និងការសម្លាប់ខ្មែរក្រោម និងវៀតណាមនៅសហករណ៍ធិបតី[5]។
- **អង្គហេតុទី ៤**-ការចោទប្រកាន់ទាំងអស់ទាក់ទងនឹងមន្ទីរសន្តិសុខវត្តបន្ទាយត្រែង[6]។
- **អង្គហេតុទី ៥**-ការចោទប្រកាន់អំពីការសម្លាប់រង្គាលនៅភ្នំត្រដាក់ចិត្ត[7]។
- **អង្គហេតុទី៦**-ការចោទប្រកាន់ទាំងអស់ទាក់ទងនឹងទីតាំងសម្លាប់មនុស្សដំណាក់វាំង[8]។
- **អង្គហេតុទី ៧**-ការចោទប្រកាន់ទាំងអស់ទាក់ទងនឹងគុកត្រាចក្រោល ហៅ គុកបឹងបាតកណ្តាល[9]។

---

[1]សំណុំរឿង ០០៤ ឯកសារ D302 *សំណើសុំមតិយោបល់ទាក់ទងនឹងការចោទប្រកាន់អំពីអង្គហេតុដែលនឹងមិនស៊ើបអង្កេតថែមទៀតទេ* ថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ២០១៦ ("សំណើសុំមតិយោបល់")។

[2]គួរកត់សម្គាល់ថា ការចោទប្រកាន់នានាគឺសំដៅលើអង្គហេតុមួយ។

[3]សំណុំរឿង០០៤ ឯកសារ D65 *ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញាទាក់ទងនឹងទីតាំងឧក្រិដ្ឋកម្មនានានៅក្នុងតំបន់១ និងការធ្វើទុក្ខបុកម្នេញចំពោះខ្មែរក្រោម* ថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ២០១១ ("ដីកាសន្និដ្ឋានបន្ថែមទី ១") កថាខណ្ឌ ១២។

[4]ដីកាសន្និដ្ឋានបន្ថែមទី ១ កថាខណ្ឌ ១២។

[5]សំណុំរឿង០០៤ ឯកសារ D191 *ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញាទាក់ទងនឹងអាពាហ៍ពិពាហ៍ដោយបង្ខំ និងអំពើហិង្សាយេនឌ័រ* ថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០១៤("ដីកាសន្និដ្ឋានបន្ថែមទី ២") កថាខណ្ឌ ៨។

[6] សំណុំរឿង០០៤ ឯកសារD1*ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី៣* ថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៨ កថាខណ្ឌ ៦២។

[7]ដីកាសន្និដ្ឋានបន្ថែមទី ១ កថាខណ្ឌ ៧។

[8]ដីកាសន្និដ្ឋានបន្ថែមទី ១ កថាខណ្ឌ ៩។

- **អង្គហេតុទី** ៨-ការចោទប្រកាន់ទាំងអស់ទាក់ទងនឹងល្អាងគួយឃំ[10]។
- **អង្គហេតុទី** ៩-ការចោទប្រកាន់ទាក់ទងនឹងការដាក់គោលដៅ ការចាប់ខ្លួន និងការសម្លាប់ជនជាតិវៀតណាមនៅក្នុងឃុំរាំងកេសី[11]។
- **អង្គហេតុទី** ១០- ការចោទប្រកាន់ទាក់ទងនឹងការរំលោភផ្លូវភេទ និងការសម្លាប់នារីពីរនាក់ដែលមានដើមកំណើតជាជនជាតិវៀតណាមនៅស្រុកព្រះនេត្រព្រះ[12]។
- **អង្គហេតុទី** ១១-ការចោទប្រកាន់អំពីអំពើហិង្សាផ្លូវភេទ រួមមានការរំលោភ សម្លាប់នារីខ្មែរក្រោម និង"អ្នកជម្លៀសមកពីភូមិភាគបូព៌ា"នៅស្រុកបាកាន[13]។
- **អង្គហេតុទី** ១២-ឧក្រិដ្ឋកម្មទាំងអស់ដែលបានចោទទាក់ទងនឹងទីតាំងសម្លាប់មនុស្សទួលពោធិ៍ជ្រៃ[14]។
- **អង្គហេតុទី** ១៣- ការចោទប្រកាន់អំពីការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំនៅជិតទំនប់កង្ហត[15]។

២. ខ្ញុំបានកត់សម្គាល់ថា អង្គហេតុដែលបានលើកឡើងខាងលើ ជាបឋម ហាក់ស្តែងឱ្យឃើញថាអាចត្រូវលើកលែងការចោទប្រកាន់មួយចំនួន ក្រៅពីអង្គហេតុទី ១៣ ដែលអាចជាករណីមួយសម្រាប់អនុវត្តវិធានផ្ទៃក្នុង ៦៦*ស្ទួន*[16]។ ខ្ញុំបានអញ្ជើញភាគីទាំងអស់ ឱ្យដាក់សារណាថាតើខ្លួនយល់ឃើញថា ការលើកលែងការចោទប្រកាន់យោងតាមវិធានផ្ទៃក្នុង ៦៧(៣) និង/ឬ ការអនុវត្តវិធានផ្ទៃក្នុង ៦៦*ស្ទួន* គឺជាត្រឹមត្រូវដែរឬអត់ចំពោះអង្គហេតុទី ១ ដល់ ១៣[17]។

---

[9]ដីកាសន្និដ្ឋានបន្ថែមទី ១ កថាខណ្ឌ ១៦។

[10]ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី ៣ កថាខណ្ឌ ៧០។

[11]ដីកាសន្និដ្ឋានបន្ថែមទី ២ កថាខណ្ឌ ៨។

[12]ដីកាសន្និដ្ឋានបន្ថែមទី ២ កថាខណ្ឌ ៩។

[13]ដីកាសន្និដ្ឋានបន្ថែមទី ២ កថាខណ្ឌ ៧។

[14]ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី ៣ កថាខណ្ឌ ៧៣។ ដីកាសន្និដ្ឋានបន្ថែមទី ១ កថាខណ្ឌ ១៨-១៩។

[15]សំណុំរឿង00៤ ឯកសារ D272/1 *ចម្លើយតបទៅនឹងដីកាបញ្ជូនសំណុំរឿងទៅពិនិត្យចុះថ្ងៃទី ៥ ខែ វិច្ឆិកា ឆ្នាំ ២០១៥ និងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមពាក់ព័ន្ធនឹងវិសាលភាពនៃកិច្ចស៊ើបសួរលើអាពាហ៍ពិពាហ៍ដោយបង្ខំនៅក្នុងតំបន់ ១ និងតំបន់ ៤* ថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០១៥ ("ដីកាសន្និដ្ឋានបន្ថែមទី ៤") កថាខណ្ឌ ៦។

[16]សំណើសុំមតិយោបល់ កថាខណ្ឌ ៥។

[17]សំណើសុំមតិយោបល់ កថាខណ្ឌ ១០។

៣. នៅថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ២០១៦ យឹម ទិត្យ បានស្នើសុំឱ្យលើកលែងការចោទប្រកាន់មួយចំនួនភ្លាមៗចំពោះអង្គហេតុទី ១ ដល់ ១៣ យោងតាមវិធានផ្ទៃក្នុង ៦៧(៣) ពីព្រោះថា ការលើកលែងការចោទប្រកាន់បែបនេះនឹងជួយជាប្រយោជន៍ដល់ល្បឿន និងប្រសិទ្ធផលកិច្ចដំណើរការនីតិវិធី ការពារប្រយោជន៍របស់គាត់តាមវិធានផ្ទៃក្នុង ២១ និងបង្រួមគោលដៅស៊ើបសួរ[18]។

៤. យឹម ទិត្យ ក៏បានអះអាងថា វិធានផ្ទៃក្នុង ៦៦ *ស្ទួន* មិនគួរយកមកអនុវត្តឡើយក្នុងករណីដែលមានភស្តុតាងមិនគ្រប់គ្រាន់ ឬក៏អង្គហេតុស្ថិតនៅក្រៅវិសាលភាពពេលវេលា[19]។

៥. នៅថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០១៦ សហព្រះរាជអាជ្ញាអន្តរជាតិ(“ស.ព.អ”)បានដាក់ចម្លើយតបរបស់ខ្លួន[20] ដោយបញ្ជាក់ថា អង្គហេតុទី ៨, ១០ និង ១២ មិនតម្រូវឱ្យមានការស៊ើបអង្កេតថែមទៀតឡើយ ហើយគាត់នឹងមិនជំទាស់ទៅនឹងការលើកលែងការចោទប្រកាន់ចំពោះអង្គហេតុទាំងនេះយោងតាមវិធានផ្ទៃក្នុង ៧៦(៣) ឬការដកចេញអង្គហេតុទាំងនេះតាមវិធានផ្ទៃក្នុង ៦៦*ស្ទួន* ឡើយ[21]។ ប៉ុន្តែ អង្គហេតុទី ១, ៧ និង ៩ គួរតែស៊ើបអង្កេតបន្ថែមទៀត ពីព្រោះថា អង្គហេតុទាំងនេះគឺ “ពាក់ព័ន្ធយ៉ាងជិតស្និទ្ធិទៅនឹងទីតាំងឧក្រិដ្ឋកម្មដែលស្ថិតក្នុងស្រុកនីមួយៗ”[22]។ ចុងក្រោយ ការស៊ើបអង្កេតលើអង្គហេតុទី ៦, ១១ និង ១៣ ក៏គួរបន្តផងដែរពីព្រោះថា មានបញ្ហាដែលមិនទាន់បានដោះស្រាយ[23]។

---

[18]សំណុំរឿង ០០៤ ឯកសារ D302/1 *សារណារបស់ យឹម ទិត្យ ទាក់ទងនឹងការចោទប្រកាន់អំពីអង្គហេតុដែលនឹងមិនស៊ើបអង្កេតបន្ថែមទៀត* ថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ២០១៦ (“សារណារបស់ យឹម ទិត្យ អំពីអង្គហេតុចំនួន ១៣”)។

[19]សារណារបស់ យឹម ទិត្យ អំពីអង្គហេតុចំនួន ១៣ កថាខណ្ឌ ១៦។

[20]សំណុំរឿង ០០៤ ឯកសារ D302/2 *ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងសំណើរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិសុំយោបល់ទាក់ទងនឹងការចោទប្រកាន់អំពីអង្គហេតុដែលនឹងមិនស៊ើបអង្កេតបន្ថែម* ថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០១៦ (“ចម្លើយរបស់ ស.ព.អ អំពីអង្គហេតុចំនួន ១៣”)។

[21]ចម្លើយរបស់ ស.ព.អ អំពីអង្គហេតុចំនួន ១៣ កថាខណ្ឌ ១៧។

[22]ចម្លើយរបស់ ស.ព.អ អំពីអង្គហេតុចំនួន ១៣ កថាខណ្ឌ ១៨។ សូមមើល កថាខណ្ឌ ១៩ សម្រាប់អង្គហេតុទី ១ និង ២ កថាខណ្ឌ ២០ សម្រាប់អង្គហេតុទី ៤ ដល់ ៧ និងកថាខណ្ឌ ២១ សម្រាប់អង្គហេតុទី ៣ និង ៩។

[23]ចម្លើយរបស់ ស.ព.អ អំពីអង្គហេតុចំនួន ១៣ សូមមើលកថាខណ្ឌ ២២ សម្រាប់អង្គហេតុទី ៦ កថាខណ្ឌ ២៣ សម្រាប់អង្គហេតុទី ១១ និង កថាខណ្ឌ ២៤ សម្រាប់អង្គហេតុទី ១៣។

01321886



៦. បន្ថែមពីលើនេះទៀត ស.ព.អ អះអាងថា វិធានផ្ទៃក្នុង ៦៦*ស្ទួន* គួរយកមកអនុវត្តចំពោះអង្គហេតុបន្ថែមទៀតនៅក្នុងដីកាសន្និដ្ឋាន និងចម្លើយតបរបស់ ស.ព.អ ទៅនឹងដីកាបញ្ជូនសំណុំរឿងទៅពិនិត្យ D196 [24] ពោលគឺការចោទប្រកាន់ទាំងអស់ទាក់ទងនឹងទីតាំងនានានៅក្នុងសំណុំរឿង ០០៤/០១ ប្រឆាំងនឹង អ៊ឹម ចែម នៅតំបន់ ៥ ភូមិភាគពាយ័ព្យ គឺ មន្ទីរសន្តិសុខ និងការដ្ឋានភ្នំទ្រយោង ការដ្ឋានស្ពានស្រែង ការដ្ឋានទំនប់ព្រៃរនាម វត្តព្រះនេត្រព្រះ និងទីតាំងសម្លាប់មនុស្ស និងឃុំខ្លួនពាក់ព័ន្ធនានា មន្ទីរសន្តិសុខ និងទីតាំងសម្លាប់មនុស្សភូមិចក្រី ទីតាំងសម្លាប់ព្រៃតារ៉ូត ទីតាំងសម្លាប់មនុស្សវត្តចម្ការខ្នុរ និងការដ្ឋានទំនប់ត្រពាំងថ្ម (“**អង្គហេតុទី ១៤**”)។ បន្ថែមពីលើនេះទៀត គឺ គុកលេខ ៨ នៅតំបន់ ៧ ភូមិភាគពាយ័ព្យ (“**អង្គហេតុទី ១៥**”) មន្ទីរសន្តិសុខវត្តបន្ទាយនាង នៅតំបន់ ៣ ភូមិភាគពាយ័ព្យ(“**អង្គហេតុទី ១៦**”) និងទីតាំងសម្លាប់មនុស្សព្រៃសុខុន និងវត្តអង្គស្រីមុន្នី នៅតំបន់ ១៣ ភូមិភាគនិរតី (“**អង្គហេតុទី ១៧**”)[25]។

៧. ស.ព.អ ក៏បានអះអាងថា វិធានផ្ទៃក្នុង ៦៦*ស្ទួន* គួរយកមកអនុវត្តក្នុងករណីដែលមានភស្តុតាងមិនគ្រប់គ្រាន់ដើម្បីគាំទ្រដីកាសន្និដ្ឋាន ពីព្រោះថា ខ្ញុំ“*ធ្វើការសម្រេចចិត្តតាមឆន្ទានុសិទ្ធិដើម្បីបញ្ឈប់ការស៊ើបអង្កេតមុនពេល*”[26]។

## II. ពិភាក្សា

### i. <u>វិធានផ្ទៃក្នុង ៦៦*ស្ទួន* និង ៦៧</u>

៨. ពេលវេលាសម្រាប់សម្រេចលើការអនុវត្តវិធានផ្ទៃក្នុង ៦៦*ស្ទួន* ឬការលើកលែងការចោទប្រកាន់យោងតាមវិធានផ្ទៃក្នុង ៦៧ គឺនៅពេលបញ្ចប់កិច្ចស៊ើបសួរ។

៩. មុនពេលកាត់បន្ថយវិសាលភាពនៃកិច្ចស៊ើបសួរ យោងតាមវិធានផ្ទៃក្នុង ៦៦*ស្ទួន*(២) ខ្ញុំត្រូវជូនដំណឹងអំពីព័ត៌មានលម្អិតស្តីពីគោលបំណងនៃការកាត់បន្ថយទៅភាគីទាំងអស់ បន្ទាប់មក ភាគីនឹងមានពេល ១៥ ថ្ងៃដើម្បីដាក់សារណា។ ដូចគ្នានេះដែរ ក្នុងករណីដែលខ្ញុំយល់ឃើញថា កិច្ច

---

[24]សំណុំរឿង ០០៤ ឯកសារ D196/1 *ចម្លើយតបទៅនឹងដីកាបញ្ជូនសំណុំរឿងទៅពិនិត្យ D196* ថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ២០១៤ កថាខណ្ឌ ២ (“ចម្លើយរបស់ ស.ព.អ ទៅនឹងដីកាបញ្ជូនសំណុំរឿងទៅពិនិត្យ D196”)។

[25]សូមមើល ចម្លើយរបស់ ស.ព.អ អំពីអង្គហេតុចំនួន ១៣ កថាខណ្ឌ ២៥។

[26]ចម្លើយរបស់ ស.ព.អ អំពីអង្គហេតុចំនួន ១៣ កថាខណ្ឌ ១៥។

01321887



ស៊ើបសួរ បានបញ្ចប់ហើយ ខ្ញុំត្រូវជូនដំណឹងភាគីទាំងអស់យោងតាមវិធានផ្ទៃក្នុង ៦៦(១)។ ការជូនដំណឹងនេះនាំឱ្យមានការកំណត់កាលបរិច្ឆេទជាបន្តបន្ទាប់សម្រាប់ដាក់សំណើសុំបំពេញកិច្ចស៊ើបសួរ ដីកាបង្គាប់ និងបណ្តឹងឧទ្ធរណ៍ដែលអាចមាន ព្រមទាំងដីកាសន្និដ្ឋានស្ថាពរពី ក.ស.ព យោងតាមវិធានផ្ទៃក្នុង ៦៦។

១០. ខ្ញុំកត់សម្គាល់លើទឡ្ហីករណ៍របស់ ស.ព.អ និង យឹម ទិត្យ ទាក់ទងនឹងភាពអាចទទួលយកការប្រើប្រាស់វិធានផ្ទៃក្នុង ៦៦*ស្ទួន* ក្នុងករណីដែលមានភស្តុតាងមិនគ្រប់គ្រាន់[27] ឬអង្គហេតុស្ថិតនៅក្រៅវិសាលភាពពេលវេលា[28] និងសំណើរបស់ យឹម ទិត្យ សុំលើកលែងការចោទប្រកាន់មួយចំនួន ហើយខ្ញុំនឹងពិចារណាលើទឡ្ហីករណ៍ និងសំណើនោះឱ្យបានត្រឹមត្រូវក្នុងពេលវេលាសមស្រប។

១១. ជាចុងក្រោយ ខ្ញុំយល់ឃើញថា វិធានផ្ទៃក្នុង ៦៦*ស្ទួន* (៥) បញ្ជាក់យ៉ាងច្បាស់ថា នៅពេលដែលដកចេញអង្គហេតុ ភស្តុតាងទាក់ទងនឹងអង្គហេតុទាំងនេះនៅតែអាចពឹងផ្អែកបានចំពោះចំណុចណាដែលពាក់ព័ន្ធនឹងអង្គហេតុដែលនៅសេសសល់។ តាមការយល់ឃើញរបស់ខ្ញុំ វិធីនេះក្នុងករណីដែលមានកាលៈទេសៈប្រែប្រួលចាំបាច់ គឺត្រូវអនុវត្តចំពោះភស្តុតាងជាគ្រឹះនៃអង្គហេតុដែលអាចត្រូវលើកលែងការចោទប្រកាន់មួយចំនួន យោងតាមវិធានផ្ទៃក្នុង ៦៧។

១២. ប៉ុន្តែ កិច្ចស៊ើបសួរដ៏ស្មុគស្មាញណាមួយ ជាពិសេសកិច្ចស៊ើបសួរប្រឆាំងនឹងសាវតារស្ថាប័ន ដោយសារថា កិច្ចស៊ើបសួរបែបនេះកើតឡើងជាទូទៅនៅក្រោមក្របខណ្ឌអង្គច្បាប់ និងអង្គហេតុរបស់ អ.វ.ត.ក ទើបកិច្ចស៊ើបសួរបែបនេះតម្រូវឱ្យមានដំណោះស្រាយប្រាកដនិយម។ ហេតុនេះ ជាក់ស្តែង មិនត្រូវចេញសេចក្តីជូនដំណឹងជាផ្លូវការតាមវិធានផ្ទៃក្នុង ៦៦*ស្ទួន* (២) ដែលនឹងបើកផ្លូវឱ្យមានរយៈពេល ១៥ ថ្ងៃដើម្បីដាក់សារណាពីភាគីទាំងឡាយឡើយ ហើយអាចបណ្តាលឱ្យមានបណ្តឹងរារាំងថែមទៀតដែលក្រោយមកអាចយល់ឃើញថា មិនចាំបាច់មានបណ្តឹងបែបនោះឡើយ ហើយក៏មិនគួរប្រើប្រាស់នីតិវិធីលើកលែងការចោទប្រកាន់មួយចំនួនដែរសម្រាប់ពេលឥឡូវនេះ ដែលនីតិវិធីបែបនេះនឹងមិនតម្រូវឱ្យមានអ្វីទេក្រៅពីចាប់ផ្តើម

[27]ចម្លើយរបស់ ស.ព.អ អំពីអង្គហេតុចំនួន ១៣ កថាខណ្ឌ ១៥ និងសារណារបស់ យឹម ទិត្យ អំពីអង្គហេតុចំនួន ១៣ កថាខណ្ឌ ១៦។

[28]សារណារបស់ យឹម ទិត្យ អំពីអង្គហេតុចំនួន ១៣ កថាខណ្ឌ ១៦។

នីតិវិធីតាមវិធានផ្ទៃក្នុង ៦៦ ហើយនាំឱ្យមានដីកាដោះស្រាយលើបទចោទមួយចំនួនយោងតាមវិធានផ្ទៃក្នុង ៦៧។ បើប្រៀបធៀបជាមួយនឹងការប្រើប្រាស់នីតិវិធីបែបនេះ ការបង្ហាញអំពីគោលបំណងរបស់ខ្ញុំក្នុងការប្រើប្រាស់ធនធានសម្រាប់កិច្ចស៊ើបសួរដែលនៅសេសសល់វិញនឹងទទួលបានប្រសិទ្ធភាពការងារច្រើនជាង។ យឹម ទិត្យ មិនមានសិទ្ធិទទួលបានដីកាសម្រេចលើបទចោទមួយចំនួនបែបនោះឡើយ។

១៣. ហេតុនេះ នៅក្នុងសេចក្តីជូនដំណឹងនេះ បន្ទាប់ពីបានពិចារណាលើទឡ្ហីករណ៍របស់ភាគី ខ្ញុំបង្ហាញអំពីមូលហេតុនៃគោលបំណងបច្ចុប្បន្នរបស់ខ្ញុំទាក់ទងនឹងអង្គហេតុទី ១ ដល់ ១៧ ជាជាងជូនដំណឹងជាផ្លូវការអំពីការកាត់បន្ថយវិសាលភាពនៃកិច្ចស៊ើបសួរយោងតាមវិធានផ្ទៃក្នុង ៦៦*ស្ទួន* (២) ឬអំពីការបញ្ចប់កិច្ចស៊ើបសួរលើអង្គហេតុណាមួយយោងតាមវិធានផ្ទៃក្នុង ៦៦។

១៤. បច្ចុប្បន្ននេះ អង្គហេតុទី ១ ដល់ ១៧ ស្ថិតនៅក្នុងអង្គហេតុបីប្រភេទដូចខាងក្រោម៖

ក. ប្រភេទ ក៖ អង្គហេតុដែលជាបឋមស្តែងឱ្យឃើញថាអាចត្រូវអនុវត្តវិធានផ្ទៃក្នុង ៦៦*ស្ទួន* ហើយការស៊ើបអង្កេតលើអង្គហេតុទាំងនេះនឹងត្រូវផ្អាក (អង្គហេតុទី ៦, ១៣ និង ១៤)

ខ. ប្រភេទ ខ៖អង្គហេតុដែលជាបឋមស្តែងឱ្យឃើញថាអាចត្រូវលើកលែងការចោទប្រកាន់មួយចំនួនយោងតាមវិធានផ្ទៃក្នុង ៦៧ ហើយការស៊ើបអង្កេតលើអង្គហេតុទាំងនេះនឹងត្រូវផ្អាក (អង្គហេតុទី ១ ដល់ ៥, អង្គហេតុទី ៧ ដល់ ៩, ១០ និង ១២)។

គ. ប្រភេទ គ៖ អង្គហេតុដែលនឹងស៊ើបអង្កេតថែមទៀត (អង្គហេតុទី ១១ និង ១៥ ដល់ ១៧)។

១៥. ក្នុងករណីដែលបានផ្អាកហើយ កិច្ចស៊ើបសួរក៏អាចបើកស៊ើបសួរឡើងវិញបានដែរប្រសិនបើកាលៈទេសៈតម្រូវឱ្យធ្វើដូច្នេះ។ ក្នុងករណីបែបនេះ ភាគីទាំងអស់នឹងត្រូវផ្តល់ជូននូវពេលវេលាគ្រប់គ្រាន់ដើម្បីសម្របសម្រួលការងាររបស់ខ្លួនជាមួយនឹងកាលៈទេសៈដែលបានប្រែប្រួលបែបនេះ(ការផ្អាកកិច្ចស៊ើបសួរបណ្តោះអាសន្ន)។

១៦. ខ្ញុំបានប្រកាន់យកវិធីផ្អាកបណ្តោះអាសន្ននេះ ដែលមិនមានចែងច្បាស់លាស់នៅក្នុងវិធានផ្ទៃ

01321889



ក្នុងនោះទេ គឺដើម្បីផ្តល់ជូនភាគីទាំងអស់ ឱ្យទទួលបានការធានា និងភាពច្បាស់លាស់ជាអតិបរមាអំពីបញ្ហានានាដែលភាគីទាំងអស់ និងខ្ញុំ នឹងចាំបាច់ត្រូវចាត់ចែងធនធានមានកំណត់របស់យើង និងដើម្បីឱ្យកិច្ចស៊ើបសួរដំណើរការទៅប្រកបដោយប្រសិទ្ធភាពឱ្យបានមុនពេលកាលបរិច្ឆេទកំណត់ជាផ្លូវការតាមវិធានផ្ទៃក្នុង ៦៦*ស្ទួន* និងការបញ្ចប់កិច្ចស៊ើបសួរ។

ii. <u>ប្រភេទ ក៖ អង្គហេតុទី ៦, ១៣ និង ១៤</u>

*អង្គហេតុទី ៦*

១៧. ស.ព.អ ចោទថា យឹម ទិត្យ ទទួលខុសត្រូវ[29]ចំពោះការសម្លាប់អ្នកជាប់ឃុំជាច្រើននាក់នៅមន្ទីរសន្តិសុខបាណន់ តំបន់ ១ ភូមិភាគពាយ័ព្យ នៅដំណាក់រៀង ជិត ប៉ៃលិន[30]។ ស.ព.អ មិនបានបញ្ជាក់ឱ្យច្បាស់អំពីពេលវេលាជាក់លាក់ចំពោះឧក្រិដ្ឋកម្មទាំងនេះឡើយ ប៉ុន្តែ ហាក់ដូចជាចង់បង្ហាញថា ឧក្រិដ្ឋកម្មទាំងនោះបានកើតឡើងនៅឆ្នាំ ១៩៧៨ គឺពេលដែល យឹម ទិត្យ ត្រូវបានចោទថាធ្វើជាលេខាតំបន់ ១[31] ហើយជាអ្នកជំរុញឱ្យប្រព្រឹត្តសហឧក្រិដ្ឋកម្មរួមចាប់ផ្តើមតាំងពីពាក់កណ្តាល ឆ្នាំ ១៩៧៧[32]។

១៨. ទីតាំងសម្លាប់មនុស្សដែលបានចោទនេះមិនអាចរកឃើញឡើយ ហេតុនេះ មានភស្តុតាងមិនគ្រប់គ្រាន់ដើម្បីគាំទ្រការចោទប្រកាន់ទាំងនេះឡើយ[33]។ ស.ព.អ ផ្តល់អនុសាសន៍ឱ្យចាត់វិធានការស៊ើបសួរថែមទៀតដើម្បីស្វែងរកទីតាំងសម្លាប់មនុស្សនោះ រាប់បញ្ចូលទាំងការសាកសួរនៅឃុំដែលនៅសេសសល់ទាំងអស់នៅខេត្តប៉ៃលិន[34] សរុបមាន ៧ ឃុំ[35]។

---

[29]ដីកាសន្និដ្ឋានបន្ថែមទី ១ កថាខណ្ឌ ២១ និង ២៣។

[30]ដីកាសន្និដ្ឋានបន្ថែមទី១ កថាខណ្ឌ ៩។ សូមមើលផងដែរ ចម្លើយរបស់ ស.ព.អ អំពីអង្គហេតុចំនួន ១៣ កថាខណ្ឌ ២២។

[31]ដីកាសន្និដ្ឋានបន្ថែមទី ១ កថាខណ្ឌ ១០។

[32]ដីកាសន្និដ្ឋានបន្ថែមទី ១ កថាខណ្ឌ ២១ ស្របគ្នានឹងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី ៣ កថាខណ្ឌ ៩៤។

[33]សំណើសុំមតិយោបល់ កថាខណ្ឌ ៣។ សូមមើលផងដែរ សំណុំរឿង 00៤ ឯកសារ D105/21 *របាយការណ៍អនុវត្តដីកាចាត់ឱ្យស៊ើបសួរជំនួស* ថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០១២ ទំព័រ ៣ [អង់គ្លេស]។ សំណុំរឿង 00៤ ឯកសារ D118/121 *កំណត់ហេតុនៃកិច្ចស៊ើបសួរ* ថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១៣ ទំព័រ ២ [អង់គ្លេស]។

[34]ចម្លើយតបរបស់ ស.ព.អ អំពីអង្គហេតុចំនួន ១៣ កថាខណ្ឌ ២២។

[35]ឃុំអូរតាវៅ ឃុំ ទួលល្វា និងឃុំ បយ៉ាខា នៅស្រុកប៉ៃលិន និងឃុំសាលាក្រៅ ឃុំស្ទឹងត្រង់ ឃុំស្ទឹងកាច់ និងឃុំអូរអណ្តូង នៅស្រុកសាលាក្រៅ។

១៩. យឹម ទិត្យ ត្រូវបានដាក់ឱ្យស្ថិតក្រោមការពិនិត្យពីបទចោទថាបានធ្វើមនុស្សឃាត ការសម្លាប់រង្គាល ព្រមទាំងការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយមកលើកម្មាភិបាលពាយ័ព្យ គ្រួសាររបស់ពួកគេ និងអ្នកក្រោមបង្គាប់របស់ពួកគេ តាមរយៈបទល្មើសនៃការធ្វើមនុស្សឃាត និងការសម្លាប់រង្គាល តាមរយៈការប្រព្រឹត្តិសហឧក្រិដ្ឋកម្មរួមនៅមន្ទីរសន្តិសុខបាណាន់[36]។ យឹម ទិត្យ ត្រូវបានដាក់ឱ្យស្ថិតក្រោមការពិនិត្យពីបទចោទថាបានប្រព្រឹត្តឧក្រិដ្ឋកម្មដើម្បីអនុវត្តផែនការរួមដែលអាចកើតឡើងតាំងពីដើមឆ្នាំ ១៩៧៧ ឬពាក់កណ្តាលឆ្នាំ ១៩៧៧ រហូតដល់យ៉ាងហោចណាស់ថ្ងៃទី ០៦ ខែ មករា ឆ្នាំ ១៩៧៩[37]។

២០. ទោះបីជាដកចេញអង្គហេតុប្រភេទ ទី ៦ នៅពេលបញ្ចប់កិច្ចស៊ើបសួរ ក៏អង្គហេតុនៅសេសសល់ទាំងអស់ទាក់ទងនឹងមន្ទីរសន្តិសុខបាណាន់ ទំនងជានៅតែតំណាងឱ្យវិសាលភាពនៃដីកាសន្និដ្ឋានផ្នែកភូមិសាស្ត្រ ពេលវេលា និងខ្លឹមសារ។ ជាពិសេស អង្គហេតុដែលនៅសេសសល់ទាំងអស់ គួរតែតំណាងឱ្យលក្ខណៈ និងទំហំនៃឧក្រិដ្ឋកម្ម ព្រមទាំងប្រភេទជនរងគ្រោះ។

*អង្គហេតុទី ១៣*

២១. ស.ព.អ ចោទថា យឹម ទិត្យ ទទួលខុសត្រូវ[38]ចំពោះការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំនៅទំនប់កង្កួត[39] នៅតំបន់ ១។ ការចោទប្រកាន់នេះគឺផ្អែកលើហេតុការណ៍នៃការរៀបការដោយបង្ខំសម្រាប់ប្តីប្រពន្ធ ១៥ គូនៅឆ្នាំ ១៩៧៨ ដែលអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីម្នាក់ បានរៀបរាប់នៅក្នុងពាក្យសុំរបស់គាត់[40]។

---

[36]សំណុំរឿង ០០៤ ឯកសារ D281 *កំណត់ហេតុនៃការបង្ហាញខ្លួនលើកដំបូង* ថ្ងៃទី ០៩ ខែ ធ្នូ ឆ្នាំ ២០១៥ (“ការបង្ហាញខ្លួនលើកដំបូង”) ទំព័រ ១៣។

[37]ការបង្ហាញខ្លួនលើកដំបូង កថាខណ្ឌ ២៣-២៥។

[38]ដីកាសន្និដ្ឋានបន្ថែមទី ២ កថាខណ្ឌ ១៤។ ដីកាសន្និដ្ឋានបន្ថែមទី ៤ កថាខណ្ឌ ១៤។

[39]ដីកាសន្និដ្ឋានបន្ថែមទី ៤ កថាខណ្ឌ ៦។

[40]សំណុំរឿង ០០៤ ឯកសារ D65.1.1.5.a *ឯកសារភ្ជាប់ទី ៥៖ ទម្រង់បែបបទសុំព័ត៌មានបន្ថែមសម្រាប់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី* ថ្ងៃទី ១៦ ខែ មករា ឆ្នាំ ២០១០។ សូមមើលផងដែរ សំណុំរឿង ០០៤ ឯកសារ D219/647 *កំណត់ហេតុនៃកិច្ចស៊ើបសួរ* ថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០១០។

២២. ស.ព.អ អះអាងថា ការស៊ើបអង្កេតលើអង្គហេតុនេះគួរបន្ត ពីព្រោះថា អង្គហេតុនេះបានកើតឡើងនៅ "ជិតគ្នា"នឹងការដ្ឋានទំនប់កង្កួត ហើយអាចពាក់ព័ន្ធនឹងតួនាទីរបស់ យឹម ទិត្យ[41]។ ស.ព.អ លើកឡើងថាគួរចាត់វិធានការស៊ើបសួរបន្ថែមទៀត[42]។

២៣. យឹម ទិត្យ ត្រូវបានដាក់ឲ្យស្ថិតក្រោមការពិនិត្យពីបទចោទអំពីការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំនៅស្រុកសំឡូត តំបន់ ១ តាមរយៈការប្រព្រឹត្តិដោយផ្ទាល់[43] ព្រមទាំងនៅឃុំកំពង់ព្រៀង និងឃុំរាំងកេសី នៅតំបន់ ៤ ភូមិភាគពាយ័ព្យ តាមរយៈការរៀបចំផែនការ ការបញ្ជា ការជំរុញ ការទទួលខុសត្រូវថ្នាក់លើ និងការប្រព្រឹត្តិតាមរយៈសហឧក្រិដ្ឋកម្មរួម[44]។ យឹម ទិត្យ ត្រូវបានដាក់ឲ្យស្ថិតក្រោមការពិនិត្យពីបទចោទថាបានប្រព្រឹត្តឧក្រិដ្ឋកម្មទាំងនេះ ដើម្បីអនុវត្តផែនការរួមដែលអាចកើតឡើងតាំងពីដើមឆ្នាំ ១៩៧៧ ឬពាក់កណ្ដាលឆ្នាំ ១៩៧៧ រហូតដល់យ៉ាងហោចណាស់ថ្ងៃទី ០៦ ខែ មករា ឆ្នាំ ១៩៧៩[45]។

២៤. ទោះបីជាដកចេញអង្គហេតុ ទី ១៣ នៅពេលបញ្ចប់កិច្ចស៊ើបសួរ ក៏អង្គហេតុនៅសេសសល់ទាំងអស់ទាក់ទងនឹងស្រុកសំឡូត ព្រមទាំងឃុំកំពង់ព្រៀង និងឃុំរាំងកេសី ទំនងជានៅតែតំណាងឲ្យវិសាលភាពនៃដីកាសន្និដ្ឋានផ្នែកភូមិសាស្ត្រ ពេលវេលា និងខ្លឹមសារ។ ជាពិសេសអង្គហេតុដែលនៅសេសសល់ទាំងអស់ គួរតែតំណាងឲ្យលក្ខណៈ និងទំហំនៃឧក្រិដ្ឋកម្មព្រមទាំងប្រភេទជនរងគ្រោះ។

*អង្គហេតុទី ១៤*

២៥. ស.ព.អ ចោទថា យឹម ទិត្យ ទទួលខុសត្រូវ[46]ចំពោះការឃុំខ្លួន ពលកម្មដោយបង្ខំ ការសម្លាប់ ការដាក់មុខសញ្ញាលើកម្មាភិបាលភូមិភាគពាយ័ព្យ និងអ្នកពាក់ព័ន្ធជាមួយពួកគេ ព្រមទាំងការ

---

[41]ចម្លើយតបរបស់ ស.ព.អ អំពីអង្គហេតុចំនួន ១៣ កថាខណ្ឌ ២៤។

[42]ចម្លើយតបរបស់ ស.ព.អ អំពីអង្គហេតុចំនួន ១៣ កថាខណ្ឌ ២៤។

[43]ការបង្ហាញខ្លួនលើកដំបូង ទំព័រ ១៤។

[44]ការបង្ហាញខ្លួនលើកដំបូង ទំព័រ ១៤។

[45]ការបង្ហាញខ្លួនលើកដំបូង ទំព័រ ២៣-២៥។

[46] ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទី ៣ កថាខណ្ឌ ៩០។ សូមមើលផងដែរ ចម្លើយតបរបស់ ស.ព.អ ទៅនឹងដីកាបញ្ជូនសំណុំរឿងទៅពិនិត្យ D196។

01321892



ធ្វើបាបនៅទីតាំងនានានៅតំបន់ ៥ ភូមិភាគពាយ័ព្យ[47] ចាប់តាំងពីពាក់កណ្ដាលឆ្នាំ ១៩៧៧[48]។ គាត់អះអាងថា គាត់មិនជំទាស់មិនឱ្យដកចេញអង្គហេតុទី ១៤ យោងតាមវិធានផ្ទៃក្នុង ៦៦ *ស្ទួន* ឡើយ[49]។

២៦. ទោះបីជាដកចេញអង្គហេតុ ទី ១៤ នៅពេលបញ្ចប់កិច្ចស៊ើបសួរ ក៏អង្គហេតុនៅសេសសល់ទាំងអស់ទាក់ទងនឹងទីតាំងឧក្រិដ្ឋកម្មនានានៅតំបន់ ១, ៣ និង ៤ ភូមិភាគពាយ័ព្យ ទំនងជានៅតែតំណាងឱ្យវិសាលភាពនៃដីកាសន្និដ្ឋានផ្នែកភូមិសាស្ត្រ ពេលវេលា និងខ្លឹមសារ។ ជាពិសេស អង្គហេតុដែលនៅសេសសល់ទាំងអស់ គួរតែតំណាងឱ្យលក្ខណៈ និងទំហំនៃឧក្រិដ្ឋកម្ម ព្រមទាំងប្រភេទជនរងគ្រោះ។

iii. <u>ប្រភេទ ខ៖ អង្គហេតុទី ១ ដល់៥, ៧ ដល់ ៩, ១០ និង ១២</u>

២៧. អង្គហេតុទី ១ ដល់៥, ៧ ដល់ ៩, ១០ និង ១២ ជាបឋមស្ដែងឱ្យឃើញថាអាចត្រូវលើកលែងការចោទប្រកាន់មួយចំនួន[50]។ ខ្ញុំជឿថា ការស៊ើបអង្កេតសមហេតុផលលើអង្គហេតុទាំងនេះបានធ្វើរួចហើយ។ តាមមូលហេតុដែលបានបង្ហាញនៅក្នុងសំណើសុំមតិយោបល់[51] ខ្ញុំ មានបំណងមិនបន្តស៊ើបអង្កេតលើអង្គហេតុទី ១ ដល់៥, ៧ ដល់ ៩, ១០ និង ១២ ទៀតឡើយ។

២៨. ជាពិសេស ចំពោះអង្គហេតុមួយចំនួន ខ្ញុំបានជូនដំណឹងភាគីទាំងអស់ថា ខ្ញុំជឿថា មានភស្តុតាងមិនគ្រប់គ្រាន់ដើម្បីគាំទ្រការចោទប្រកាន់របស់ ស.ព.អ អំពីឧក្រិដ្ឋកម្មជាក់លាក់មួយចំនួនដែលបានប្រព្រឹត្តឡើងនៅទីតាំងពាក់ព័ន្ធទាំងនោះ[52]។ ស.ព.អ ហាក់ដូចជាមិនយល់ស្របតាមការវាយតម្លៃរបស់ខ្ញុំអំពីភស្តុតាងដែលមានស្រាប់ទាក់ទងនឹងអង្គហេតុទី ១ ដល់ ៤, ៧ និង ៩ ប៉ុន្តែ គាត់មិនបានបង្ហាញពីភស្តុតាងដើម្បីគាំទ្រការអះអាងដែលថា ឧក្រិដ្ឋកម្មនានាដូច

---

[47]សូមមើល ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី ៣ កថាខណ្ឌ ៧១ និង ៧៤-៧៩ និងចម្លើយតបរបស់ ស.ព.អ ទៅនឹងដីកាបញ្ជូនសំណុំរឿងទៅពិនិត្យD196 កថាខណ្ឌ ២។

[48]ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី ៣ កថាខណ្ឌ ៥៤ និង ៩៤។

[49]ចម្លើយតបរបស់ ស.ព.អ អំពីអង្គហេតុចំនួន ១៣ កថាខណ្ឌ ២៥។

[50]សំណើសុំមតិយោបល់ កថាខណ្ឌ ៥។

[51]សំណើសុំមតិយោបល់ កថាខណ្ឌ ៣។

[52]សំណើសុំមតិយោបល់ កថាខណ្ឌ ៣។

01321893



បានចោទនៅក្នុងដីកាសន្និដ្ឋាន បានប្រព្រឹត្តឡើងនៅទីតាំងជាក់លាក់ទាំងនោះឡើយ[53]។ ខ្ញុំមិនយល់ឃើញថា ភស្តុតាងដែលបញ្ជាក់ថាអាចមានឧក្រិដ្ឋកម្មនៅទីតាំងផ្សេងទៀត ដោយគ្រាន់តែថាទីតាំងបែបនោះមានទីតាំងភូមិសាស្ត្រនៅជិត អាចមានទំនាក់ទំនងជាមួយនឹងស្រុកដូចគ្នា និង/ឬនៅក្នុងស្រុកដូចគ្នានោះ គឺជាភស្តុតាងដែលគាំទ្រអង្គហេតុទី ១ ដល់ ទី៤, ៧ និង ៩ ឡើយ។

២៩. ចំពោះអង្គហេតុទី ១ ខ្ញុំកត់សម្គាល់ថា នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញាទាក់ទងនឹងទីតាំងឧក្រិដ្ឋកម្មនានានៅក្នុងតំបន់ ១ និងការធ្វើទុក្ខបុកម្នេញចំពោះខ្មែរក្រោម("ដីកាសន្និដ្ឋានបន្ថែមទី ១") ស.ព.អ ចោទ ថា ខ្មែរក្រោម ត្រូវបានសម្លាប់ និងកប់នៅវត្តសុបិន[54]។ ប៉ុន្តែ នៅក្នុងចម្លើយតបរបស់ ស.ព.អ អំពីអង្គហេតុចំនួន ១៣ ស.ព.អ យោងលើ"*ភស្តុតាងអំពីការសម្លាប់រង្គាលទៅលើទាហាន លន់ នល់ និងមេបាសិបខ្លួនចំនួន ១៨០ នៅក្នុងខែ តុលា ឆ្នាំ ១៩៧៥*"[55]។ ហេតុនេះ ដោយសារថា ដីកាសន្និដ្ឋានបន្ថែមទី ១ មិនបានលើកឡើងពីក្រុមជនរងគ្រោះផ្សេងទៀត ក្រៅពីខ្មែរក្រោម ទើបខ្ញុំមិនយល់ឃើញថា ខ្ញុំបានទទួលពិនិត្យឧក្រិដ្ឋកម្មមកលើជនផ្សេងទៀតក្រៅពីខ្មែរក្រោម នៅវត្តសុបិន ឡើយ។

៣០. ចំពោះអង្គហេតុទី ៥ ភស្តុតាងបង្ហាញថា ការសម្លាប់មនុស្សដែលបានប្រព្រឹត្តឡើងគឺនៅក្រៅយុត្តាធិការពេលវេលារបស់ អ.វ.ត.ក យោងតាមមាត្រា១ នៃច្បាប់ស្តីពីការបង្កើតអ.វ.ត.ក[56]។ ស.ព.អ មិនបានលើកឡើងពីបញ្ហាវិសាលភាពវេលានៃឧក្រិដ្ឋកម្មនេះឡើយ។ ប៉ុន្តែ គាត់បញ្ជាក់ថា អង្គហេតុទី ៥ អាចជាទីតាំងមួយសម្រាប់សម្លាប់អ្នកជាប់ឃុំមកពីមន្ទីរសន្តិសុខបាណន់ ឬមន្ទីរសន្តិសុខគាស់ក្រឡ[57]។ ខ្ញុំកត់សម្គាល់ថា យឹម ទិត្យ ត្រូវបានដាក់ឱ្យស្ថិតក្រោមការពិនិត្យពីបទចោទអំពីការធ្វើមនុស្សឃាត ការសម្លាប់រង្គាល និងការធ្វើទុក្ខបុកម្នេញតាមរយៈបទល្មើសនៃការធ្វើមនុស្សឃាត ការសម្លាប់រង្គាលតាមរយៈការរៀបចំផែនការ

---

[53]សូមមើល ចម្លើយតបរបស់ ស.ព.អ អំពីអង្គហេតុចំនួន ១៣ កថាខណ្ឌ ១៨-២១។

[54]ដីកាសន្និដ្ឋានបន្ថែមទី ១ កថាខណ្ឌ ១២។

[55]ចម្លើយតបរបស់ ស.ព.អ អំពីអង្គហេតុចំនួន ១៣ កថាខណ្ឌ ១៩។

[56]សំណើសុំមតិយោបល់ កថាខណ្ឌ ៣។

[57]ចម្លើយតបរបស់ ស.ព.អ អំពីអង្គហេតុចំនួន ១៣ កថាខណ្ឌ ២០។

01321894



ការបញ្ជា ការជំរុញ ការទទួលខុសត្រូវថ្នាក់លើ និង/ឬការប្រព្រឹត្តិតាមរយៈសហឧក្រិដ្ឋកម្មរួម នៅមន្ទីរសន្តិសុខបាណន់ ឬមន្ទីរសន្តិសុខគាស់ក្រឡ[58]។

៣១. ជាចុងក្រោយ ចំពោះអង្គហេតុទី ៨, ១០ និង ១២ ខ្ញុំកត់សម្គាល់ថា ស.ព.អ មិនជឿថា ចាំបាច់ត្រូវមានកិច្ចស៊ើបសួរបន្ថែមទៀតឡើយនៅដំណាក់កាលនេះ[59]។

iv. <u>ប្រភេទ គ៖ អង្គហេតុទី ១១ និង ១៥ ដល់ ១៧</u>

៣២. នៅដំណាក់កាលនេះនៃកិច្ចដំណើរការនីតិវិធី ខ្ញុំកត់សម្គាល់លើទឡ្ហីករណ៍របស់ភាគីទាំងឡាយ អំពីអង្គហេតុទី ១១ និង ១៥ ដល់ ១៧[60]។

៣៣. ការស៊ើបអង្កេតលើអង្គហេតុទី ១ និង ១៥ ដល់ ១៧ បានឈានចូលដល់ដំណាក់កាលខ្ពស់ ហើយ ហើយខ្ញុំមានបំណងបន្តការស៊ើបអង្កេតនេះ។ ប្រសិនបើមិនបន្តការស៊ើបអង្កេតនេះវិញ ក៏វាមិនចំណេញដល់ល្បឿននៃកិច្ចដំណើរការនីតិវិធីដែរ។

៣៤. ប្រសិនបើមានការប្រែប្រួលកាលៈទេសៈដែលធ្វើឱ្យខ្ញុំ មានការយល់ឃើញផ្សេង ខ្ញុំនឹងជូនដំណឹងភាគីទាំងអស់ក្នុងពេលវេលាសមស្រប។

**តាមសំអាងហេតុខាងលើ ខ្ញុំ៖**

៣៥. **ជូនដំណឹង** ភាគីទាំងអស់ថា ខ្ញុំនឹងមិនស៊ើបអង្កេតថែមទៀតទេលើអង្គហេតុទី ១ ដល់ ១០ និងអង្គហេតុទី១២ ដល់ ១៤ ប៉ុន្តែ ខ្ញុំនឹងបន្តស៊ើបអង្កេតលើអង្គហេតុទី១១ និង ១៥ ដល់ ១៧។

៣៦. **ជូនដំណឹង** ភាគីទាំងអស់ថា ខ្ញុំអាចសម្រេចបើកកិច្ចស៊ើបសួរឡើងវិញចំពោះអង្គហេតុទី ១ ដល់ ១០ និងអង្គហេតុទី ១២ ដល់ ១៤ ហើយក្នុងករណីបែបនោះ ខ្ញុំនឹងធានាថា ភាគីទាំងអស់ មានពេលវេលាគ្រប់គ្រាន់ដើម្បីរៀបចំរឿងក្តីរបស់ខ្លួន។

---

[58]ការបង្ហាញខ្លួនលើកដំបូង ទំព័រ ១១-១៣។

[59]ចម្លើយតបរបស់ ស.ព.អ អំពីអង្គហេតុចំនួន ១៣ កថាខណ្ឌ ១៧។

[60]សារណារបស់ យឹម ទិត្យ អំពីអង្គហេតុចំនួន ១៣ កថាខណ្ឌ ៣០ និងចម្លើយតបរបស់ ស.ព.អ អំពីអង្គហេតុចំនួន ១៣ កថាខណ្ឌ ២២ និង ២៥។

៣៧. **ជូនដំណឹង** ភាគីទាំងអស់ថា ដីកាសម្រេចលើការលើកលែងការចោទប្រកាន់មួយចំនួនយោងតាមវិធានផ្ទៃក្នុង ៦៧ ឬការអនុវត្តវិធានផ្ទៃក្នុង ៦៦*ស្ទួន* នឹងត្រូវធ្វើឡើងនៅពេលបញ្ចប់កិច្ចស៊ើបសួរ។

ភ្នំពេញ ថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ២០១៦

**ចៅក្រម Michael Bohlander**
**សហចៅក្រមស៊ើបអង្កេតអន្តរជាតិ**
**International Co- Investigating Judge**
**Co-juge d'instruction International**